# ព្រះរាជក្រឹត្យ

## ស្ដីពីការកំណត់ និងការចាត់ចែងគ្រប់គ្រង
## តំបន់សៀមរាប អង្គរ

លេខ : ០០១ ន.ស.

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងតាមសេចក្ដីស្នើសុំដាក់ប្រាសាទអង្គរ ចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក
- បានឃើញសេចក្ដីស្នើរបស់គណៈរដ្ឋមន្ត្រី

## ត្រាស់បង្គាប់

### ជំពូកមួយ
### ការកំណត់តំបន់ និងការចាត់ចែងគ្រប់គ្រងតំបន់
### សៀមរាបអង្គរ ចំណាត់ថ្នាក់រមណីយដ្ឋានវប្បធម៌ត្រូវការពារ

មាត្រា ១ : សំរេចអោយត្រួតពិនិត្យការអភិវឌ្ឍតំបន់សៀមរាប អង្គរ ដោយគោរពតាមប្លង់កំណត់តំបន់មួយ ។

មាត្រា ២ : រមណីយដ្ឋានវប្បធម៌ក្នុងប្លង់នេះត្រូវចាត់ជាប្រាំប្រភេទ ។ ប្រភេទនីមួយ ៗត្រូវទទួលការការពារខុស ៗ គ្នា :

តំបន់ ១ : រមណីយដ្ឋានមានប្រាសាទ

តំបន់ ២ : ឧទ្យានបុរាណវត្ថុ ត្រូវការពារ

តំបន់ ៣ : ទេសភាពវប្បធម៌ ត្រូវការពារ

តំបន់ ៤ : ចំណុចមានសារៈសំខាន់ ផ្នែកបុរាណវត្ថុវិទ្យា នរវិទ្យា ឬ ប្រវត្តិវិទ្យា

តំបន់ ៥ : បរិវេណអភិវឌ្ឍសង្គមសេដ្ឋកិច្ច និង វប្បធម៌ នៃតំបន់សៀមរាប អង្គរ ។

មាត្រា ៣ : តំបន់ ១

រមណីយដ្ឋានមានប្រាសាទ : គឺតំបន់នានាដែលមានស្ថានីយបុរាណវត្ថុសំខាន់ៗជាងគេក្នុងប្រទេសយើង ហើយត្រូវទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។ ធម្មតាតំបន់ទាំងអស់នេះមានទំហំតូច តែចំពោះអង្គរវិញ ទោះមានផ្ទៃដីធំធេងនោះក៏ត្រូវចាត់ចែងការពារចូលក្នុងកំរិតខ្ពស់បំផុតនេះដែរ ដោយតំបន់ នេះមានប្រាសាទ និងសំណល់បុរាណវត្ថុ ច្រើន ។

មាត្រា ៤ : តំបន់ ២

ឧទ្យានបុរាណវត្ថុត្រូវការពារ : គឺតំបន់ដែលសំបូរសំណល់បុរាណវត្ថុ ដែលត្រូវការពារទប់ទល់និងការប្រើប្រាស់ដីធ្លីផ្តេសផ្តាសនិងការអភិវឌ្ឍមិនសមស្រប ។ ធម្មតាតំបន់ទាំងនេះ ស្ថិតនៅជុំវិញរមណីយដ្ឋានមានប្រាសាទ ។ តំបន់ទាំងនេះច្រើនមានបុរាណវត្ថុបង្កប់ក្នុងដីនោះ ។ តំបន់នេះមានសារៈសំខាន់ ចម្បងដោយសារ ជាតំបន់ទ្រនាប់សំរាប់ការពាររមណីយដ្ឋានមានប្រាសាទ ។

មាត្រា ៥ : តំបន់ ៣

ទេសភាពវប្បធម៌ត្រូវការពារ : គឺតំបន់ដែលមានលក្ខណៈជាទេសភាពត្រូវការពារ ដោយហេតុថា តំបន់នេះមានទិដ្ឋភាពបរមបុរាណ ។ លើសពីនេះទៅទៀតបែបបទប្រើប្រាស់ដីធ្លី សំណង់ នៅឋាន អាគារប្រវត្តិសាស្ត្រនៅទីនោះដែលជាកេរដំណែលដ៏យូរលង់ ផ្តល់តំលៃវប្បធម៌ខ្ពស់ ឆ្លុះបញ្ចាំងអោយឃើញជីវភាពរស់នៅពីអតីតកាល ។ ទេសភាពវប្បធម៌នេះ ជាមធ្យោបាយរក្សាទស្សនវិស័យ ព្រមទាំងទំនាក់ទំនងរវាងទិដ្ឋភាពលេចធ្លោនានា ។ ទេសភាពវប្បធម៌ត្រូវការពារនេះត្រូវមានការគ្រប់គ្រងដោយច្បាប់ទំលាប់ទប់ទល់នឹងសកម្មភាពបំផ្លិចបំផ្លាញ បង្ខិនបង្ខោច ។

មាត្រា ៦ : តំបន់ ៤

ចំណុចមានសារៈសំខាន់ផ្នែកបុរាណវត្ថុវិទ្យា នរវិទ្យា ឬ ប្រវត្តិវិទ្យា :
គឺតំបន់ផ្សេងៗទៀត ដែលមានសារប្រយោជន៍ខាងបុរាណវត្ថុវិទ្យា តែមានសារៈសំខាន់កំរិតទាបជាងរមណីយដ្ឋានមានប្រាសាទ ។ តំបន់នេះត្រូវរក្សាការពារដើម្បីជាប្រយោជន៍ដល់ការស្រាវជ្រាវ ការអប់រំ ឬ ទេសចរណ៍ ។ កិច្ចការពារនិងច្បាប់ទំលាប់គ្រប់គ្រងត្រូវមានកំរិតដូចគ្នា និងឧទ្យានបុរាណវត្ថុដែរ ។

មាត្រា ៧ : តំបន់ ៥

បរិវេណអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងវប្បធម៌នៃតំបន់សៀមរាប អង្គរ :

បរិវេណនេះគ្របដណ្តប់ខេត្តសៀមរាបទាំងមូល ។ ក្នុងគោលដៅថែរក្សាបេតិកភណ្ឌវប្បធម៌ និង ធម្មជាតិ ត្រូវចាត់ចែងវិធានការដើម្បីជំរុញការអភិវឌ្ឍស្ថិតស្ថេរមួយ និង វិធានការធលាទផលប៉ះពាល់លើបរិដ្ឋាន ។

## ជំពូកពីរ
## ទិសដៅសំរាប់តំបន់ត្រូវការពារនៃអង្គរ

### មាត្រា ៨ : ការអភិវឌ្ឍ

ក្នុងកិច្ចអភិវឌ្ឍតំបន់នានា ត្រូវប្រកាន់យកទិសដៅដូចតទៅ :

ក _ ចំពោះរមណីយដ្ឋានវប្បធម៌ត្រូវការពារទាំងអស់( តំបន់ ១,២,៣,៤,៥ ) :

- រៀបចំនីតិក្រមសំរាប់ពិនិត្យឡើងវិញ និង អនុម័តគំរោងអភិវឌ្ឍ នៅក្នុងតំបន់សៀមរាបអង្គរ ។
- ធានាប្រាកដថា គំរោងអភិវឌ្ឍទាំងឡាយ :
  - _ បានគិតគូរអំពីផលប៉ះពាល់លើបរិដ្ឋាន
  - _ មានគំរោងសំរាប់ជំនួស
  - _ ថែលកយ៉ាងណាអោយផលអាស្រូវមានកំរិតទាបបំផុត ។
- ត្រូវបញ្ចូលក្នុងការវាយតំលៃ នូវផលប៉ះពាល់ដល់បរិដ្ឋានក្នុងការស្រាវជ្រាវបុរាណវត្ថុវិទ្យា នៅ តំបន់ ពាក់ព័ន្ធទាំងនោះ ។
- មុននឹងចាប់ផ្តើមដំណើរការអភិវឌ្ឍ ត្រូវធ្វើការជីកកកាយបុរាណវត្ថុមករក្សាទុកជាមុនសិន បើជាការចាំបាច់ ។

ខ _ ចំពោះតំបន់ ១ :

- ហាមឃាត់ការអភិវឌ្ឍក្នុងរមណីយដ្ឋានមានប្រាសាទ លើកលែងតែការអភិវឌ្ឍណា ដែលមានសារប្រយោជន៍សំរាប់កិច្ចការពារ និង ការលើកស្ទួយតំលៃនៃរមណីយដ្ឋាននោះ ។

គ _ ចំពោះតំបន់ ២ :

- ហាមឃាត់ការអភិវឌ្ឍក្នុងរមណីយដ្ឋានមានប្រាសាទ លើកលែងតែការអភិវឌ្ឍ ណាដែលមានសារប្រយោជន៍សំរាប់កិច្ចការពារ និង ការលើកស្ទួយតំលៃនៃស្ថានីយ៍បុរាណវត្ថុនោះ ឬ សំរាប់ការថែរក្សារបៀបរស់នៅរបស់មនុស្សនៅតំបន់នោះ ។

### មាត្រា ៩ : អំពីបុរាណវត្ថុវិទ្យា

ក្នុងសកម្មភាពផ្នែកបុរាណវត្ថុវិទ្យា ត្រូវប្រកាន់យកទិសដៅដូចតទៅ :

ក _ ចំពោះរមណីយដ្ឋានវប្បធម៌ ត្រូវការពារទាំងអស់ ( តំបន់ ១,២,៣,៤,៥ )

- ត្រូវអោយផ្អាកជាបណ្តោះអាសន្ននូវការជីកកកាយបុរាណវត្ថុទាំងឡាយរហូតដល់ ពេលមាន ប្រព័ន្ធ ច្បាប់អនុញ្ញាត និង ការតំរង់ទិសច្បាស់លាស់ ។

• រៀបចំកម្មវិធីលំអិត ដើម្បីសិរង់ពត៌មានបុរាណវត្ថុ នៅតំបន់សៀមរាបអង្គរ

• ធ្វើបញ្ជីសារពើភ័ណ្ឌស្ថានីយ៍បុរាណវត្ថុ នៅតំបន់សៀមរាបអង្គរ ហើយបញ្ចូលបញ្ជីនោះទៅក្នុងប្រព័ន្ធផ្តល់ពត៌មានភូមិសាស្ត្រអង្គរ ( GIS )។

• ធានាប្រាកដថា ពត៌មានដែលមានរួចមកហើយ ឬ ក៏មានថ្មី ស្តីអំពីស្ថានីយ៍បុរាណវត្ថុ និង ប្រាង្គប្រាសាទបានបញ្ចូលទៅក្នុងបញ្ជីសារពើភ័ណ្ឌ ហើយនិងបានបញ្ចូលទៅក្នុងប្រព័ន្ធផ្តល់ពត៌មានភូមិសាស្ត្រ អង្គរ ( GIS ) ហើយ ។

• កំណត់លក្ខណវិនិច្ឆ័យ ព្រមទាំងកម្មវិធីសំរាប់សំគាល់ស្ថានីយ៍ណា ដែលជាចំណុចមានផលប្រយោជន៍ផ្នែកបុរាណវត្ថុវិទ្យា នរវិទ្យា ឬ ប្រវត្តិវិទ្យា ។

• រៀបចំទិសដៅ និង តំរូកិច្ចព្រមព្រៀងសំរាប់ចាត់ចែងគ្រប់គ្រងស្ថានីយ៍ទាំងអស់នោះ ក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យា អប់រំ ឬ លំហែកំសាន្ត ។

• កំណត់លក្ខណវិនិច្ឆ័យព្រមទាំងកម្មវិធី សំរាប់សំគាល់ទេសភាពវប្បធម៌ត្រូវការពារ ។ កំណត់ទិសដៅ និង នយោបាយ ដើម្បីចាត់ចែងគ្រប់គ្រងទេសភាពវប្បធម៌ទាំងអស់នោះ ក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យា អប់រំ ឬ លំហែកំសាន្ត ។

• ដាក់អោយមាន អ្នកយាមល្បាត ដើម្បីថែទាំនិងការពារស្ថានីយ៍នីមួយៗ ។

ខ _ ចំពោះតំបន់ ១

• ការពារយ៉ាងមធ្យ័តបរិវេណរមណីយដ្ឋានមានប្រាសាទ ហើយគ្រប់គ្រងបរិវេណនោះក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យា អប់រំ ឬ លំហែកំសាន្ត ។

គ _ ចំពោះតំបន់ ២

• ការពារយ៉ាងមធ្យ័តស្ថានីយបុរាណវត្ថុទាំងអស់ ព្រមទាំងសំណល់វប្បធម៌ដែល ស្ថិតនៅលើដី ឬ ក្រោមដី ។

• ត្រួតពិនិត្យ និង គ្រប់គ្រងរាល់សកម្មភាពនានា ដែលអាចបណ្តាលអោយមានផលអាស្រូវដល់ស្ថានីយ៍បុរាណវត្ថុទាំងអស់នោះ ។

## មាត្រា ១០ : ការចាត់ចែងគ្រប់គ្រងទស្សនិកជន

ក្នុងកិច្ចចាត់ចែងគ្រប់គ្រងទស្សនិកជន ត្រូវប្រកាន់យកទិសដៅដូចតទៅ :

ក _ ចំពោះរមណីយដ្ឋានវប្បធម៌ត្រូវការពារទាំងអស់ ( តំបន់ ១,២,៣,៤,៥ )

• ការចេញចូលនៃសាធារណជនក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យាក្តី អប់រំក្តី និង លំហែកំសាន្តក្តី ត្រូវមានការអនុញ្ញាត ។

• ការចេញចូលរបស់ទស្សនិកជនត្រូវអនុវត្តតាមគំរោង និង ទិសដៅច្បាស់លាស់អំពីកិរិតទាំងពេលវេលាចេញ ចូល តំលៃប័ណ្ណទស្សនា ទាំងតំលៃកំសាន្តផ្សេងៗ ទៀត ។

ខ _ ចំពោះតំបន់ ១

• កំណត់ និង រៀបចំការចូលទស្សនាតាមបែបបទ ។

• បង្ហាញអោយច្បាស់វត្តមាននៃអ្នកគ្រប់គ្រង ដើម្បីផ្តល់ពត៌មាននាំមុខថែរក្សាសន្តិសុខនិងផ្តល់សេវាផ្សេងៗដល់ទស្សនិកជន ។

• កំណត់តំលៃប័ណ្ណទស្សនា ដើម្បីប្រមូលថវិកាអោយបានគ្រប់គ្រាន់ យកមកថែរក្សា និងចាត់ចែងគ្រប់គ្រង់រមណីយដ្ឋាននោះ ។

• កំរិតចំនួននិងទំហំក្រុមទស្សនិកជន ដើម្បីរក្សាគុណភាពទស្សនកិច្ច និងដើម្បីងាយស្រួលការពារប្រាង្គប្រាសាទ ទាំងឡាយ ។

• ត្រួតពិនិត្យយ៉ាងហ្មឺងហ្មាត់ការចេញចូលរថយន្ត មិនអនុញ្ញាតអោយរថយន្តទេសចរណ៍ធំៗ កំរិតល្បឿន បើកបរ តំរូវអោយរថយន្តទាំងនោះ ទៅចតនៅទីលានចំណត ។

គ _ ចំពោះតំបន់ ២

• ហាមឃាត់គ្រប់ចរាចរណ៍ណាឆ្លងកាត់តំបន់បំរុង ។

• កែលំអផ្លូវចេញចូលសំរាប់អ្នករស់នៅក្នុងតំបន់នោះ ដោយជៀសវាងការប៉ះពាល់រមណីយដ្ឋានប្រាសាទបុរាណ ។

• កំណត់ទីតាំងទទួលភ្ញៀវ ទស្សនិកជន និងទីលានចំណតនៅក្នុងតំបន់បំរុង ។

• បង្កើតអោយមានផ្លូវថ្មី ១ បានជាវង់ព័ទ្ធជុំវិញរមណីយដ្ឋានសៀមរាបអង្គរ និងបង្វែរផ្លូវជាតិលេខ ៦ អោយនៅជុំវិញមរណីយដ្ឋានក្រុមប្រាសាទរលួស ។

## មាត្រា ១១ : សំណង់ទេសចរណ៍

ចំពោះសំណង់ទេសចរណ៍ ត្រូវប្រកាន់យកទិសដៅដូចតទៅ :

### ក _ ចំពោះរមណីយដ្ឋានវប្បធម៌ត្រូវការពារទាំងអស់( តំបន់ ១,២,៣,៤,៥ )

• គ្រប់ការសាងសង់សំណង់ទេសចរណ៍ នៅក្នុងរមណីយដ្ឋានវប្បធម៌ត្រូវការពារចាំបាច់ត្រូវមានការ អនុញ្ញាត និង ប្រព្រឹត្តទៅតាមបទបញ្ជា ។

### ខ _ ចំពោះតំបន់ ១

• អនុញ្ញាតអោយតែសំណង់តិចៗ បំផុតសំរាប់ទស្សនិកជនប្រើប្រាស់ផ្ទាល់ ( តូបលក់ អាហារ និងភេសជ្ជៈ ផ្លូវថ្មើរជើង ចំណតទោចក្រយាន ចំណតរថយន្តមីនីប៊ីស ) នៅតាមប្រាសាទដែលនៅដាច់ឡែកពីគេប៉ុណ្ណោះ ។

• អនុញ្ញាតអោយមានទីលានចំណតរថយន្តយ៉ាងតិចបំផុត ។

• រៀបចំកន្លែងអោយទស្សនិកជនបានទស្សនា កំណាយខាងបុរាណវត្ថុវិទ្យា និងការងារជួសជុលប្រាសាទដែលកំពុងអនុវត្ត ។

### គ _ ចំពោះតំបន់ ២

• បន្ថយផលប៉ះពាល់បណ្តាលមកពីទេសចរណ៍ទៅលើសហគមន៍រស់នៅទីនោះ ។

• រៀបចំទីកន្លែងតូចៗ និង មជ្ឈមណ្ឌលសិប្បកម្ម ដើម្បីផ្តល់លទ្ធភាពផ្នែកសេដ្ឋកិច្ចដល់អ្នករស់នៅទីនោះ ។

## មាត្រា ១២ ៖ ការបង្ហាញរមណីយដ្ឋានវប្បធម៌

• ដើម្បីបង្ហាញរមណីយដ្ឋានវប្បធម៌ ត្រូវប្រកាន់យកទិសដៅដូចតទៅ ៖

ក _ ចំពោះរមណីយដ្ឋានវប្បធម៌ត្រូវការពារទាំងអស់ ( តំបន់ ១,២,៣,៤,៥ )

• រៀបចំផែនការ ដើម្បីបង្ហាញបុរាណវត្ថុវិទ្យា ព្រមទាំងតំបន់ការពារធម្មជាតិ និង ប្រពៃណីអ្នកស្រុកនៃតំបន់សៀមរាបអង្គរ ។

• បង្កើតមជ្ឈមណ្ឌលទទួលភ្ញៀវមួយ នៅក្រៅរមណីយដ្ឋានត្រូវការពារ ដើម្បីផ្តល់ជូនទេសចរនូវការណែនាំស្តីអំពីបេតិកភណ្ឌវប្បធម៌អង្គរ ។

ខ _ ចំពោះតំបន់ ១

• រៀបចំដំណើរទស្សនកិច្ច ដោយមានមគ្គុទ្ទេសក៍ ហើយដាក់ផ្លាកសញ្ញាបង្ហាញពីរមណីយដ្ឋានណាដែលនៅដាច់ឡែកពីគេ ។

គ _ ចំពោះតំបន់ ២

• បង្ហាញពីជីវភាពរស់នៅរបស់ប្រជាជននៅក្នុងតំបន់ និង ទិដ្ឋភាពពិសេស ដូចជាស្ទឹងសៀមរាប.ទេសភាពមើលពីលើភ្នំក្រោម ឬ ការផលិតសិប្បកម្ម ។

## មាត្រា ១៣ ៖ ការដ្ឋានយកថ្ម

ចំពោះអាជីវកម្មថ្ម ត្រូវប្រកាន់យកទិសដៅដូចតទៅ ៖

ចំពោះរមណីយដ្ឋានវប្បធម៌ត្រូវការពារទាំងអស់ ( តំបន់ ១,២,៣,៤,៥ )

• អនុញ្ញាតអោយជីកយកថ្មបាយក្រៀម និង ថ្មភក់ នៅក្នុងរមណីយដ្ឋានត្រូវការពារសំរាប់តែយកថ្មនោះ មកប្រើការជួសជុល បុរាណវត្ថុត្រូវការពារ ក្រោយពីបានធ្វើការប៉ាន់ស្មាន ផលប៉ះពាល់ទៅលើបរិដ្ឋាន ។

• ហាមឃាត់ការជីកកកាយយកដីឥដ្ឋ និង ថ្ម ក្នុងរមណីយដ្ឋាននានាត្រូវការពារដើម្បីយកទៅប្រើប្រាស់ក្នុងការស្ថាបនាផ្លូវ ។

## មាត្រា ១៤ ៖ ការចាត់ចែងទឹក

ក្នុងវិស័យការចាត់ចែងទឹក ត្រូវប្រកាន់យកទិសដៅដូចតទៅ ៖

ក _ ចំពោះរមណីយដ្ឋានវប្បធម៌ ត្រូវការពារទាំងអស់ ( តំបន់ ១,២,៣,៤,៥ )

• ជួសជុលដោយផ្នែកៗ របទាសម្ព័ន្ធធារាសាស្ត្របុរាណ និង ចាត់ចែងរបបគ្រប់គ្រងទឹកតាមសំណង់ធារាសាស្ត្រថ្មី និង មានប្រសិទ្ធភាព ។

• កាលណាការជួសជុលស្តារឡើងវិញពុំអាចធ្វើទៅកើត ជៀសវាងកុំអោយបច្ចេកវិទ្យា និង របទាសម្ព័ន្ធថ្មី ធ្វើអោយប៉ះពាល់ដល់សំណល់បុរាណវត្ថុ ។

ខ _ ចំពោះតំបន់ ១

• ថែរក្សាស្រែចាស់ដែលមានពីបុរាណ ត្រូវត្រួតពិនិត្យយ៉ាងហ្មត់ចត់បំផុតការផ្លាស់ប្តូររចនាសម្ព័ន្ធ ។

គ _ ចំពោះតំបន់ ២

• អភិវឌ្ឍធារាសាស្ត្រតូច ៗ ដើម្បីបង្កើនផលិតផលកសិកម្ម និង ដើម្បីការប្រើប្រាស់ ផ្ទាល់របស់ អ្នករស់នៅ ទីនោះដោយមិនធ្វើអោយប៉ះពាល់ដល់បុរាណវត្ថុ ។

## មាត្រា ១៥ : ការចាត់ចែងគ្រប់គ្រងទេសភាព

ក្នុងវិស័យចាត់ចែងគ្រប់គ្រងទេសភាព ត្រូវប្រកាន់យកទិសដៅដូចតទៅ :

ក _ ចំពោះរមណីយដ្ឋានវប្បធម៌ត្រូវការពារទាំងអស់ ( តំបន់១,២,៣,៤,៥ )

• ធានាប្រាកដថា គ្រប់ការអភិវឌ្ឍត្រូវតែការពារ និងបង្កើនតំលៃវប្បធម៌នៃទេសភាព ។

• ធានាប្រាកដថា គ្រប់នយោបាយ និងទិសដៅសំរាប់ការចាត់ចែងគ្រប់គ្រងទេសភាព ត្រូវបានបញ្ចូលទៅក្នុង ផែនការ និងសកម្មភាព នៃការចាត់ចែងគ្រប់គ្រងរមណីយដ្ឋាន ។

ខ _ ចំពោះតំបន់ ១

• រៀបចំបង្ហាញសភាពដើមពិត នៃបុរាណវត្ថុវិទ្យា ដោយរៀបចំទេសភាព អោយមានលក្ខណៈសមស្រប តាមបុរាណវត្ថុវិទ្យា ។

• រក្សាទុកព្រៃធម្មជាតិ ទេសភាពព្រៃឈើ ហើយនិងដាំដើមឈើ សំរាប់លំអកំសាន្ត ។

• ចាត់ចែងរៀបចំទេសភាព នៅជុំវិញប្រាសាទនានា ។

គ _ ចំពោះតំបន់ ២

• បង្កើតអោយមានតំបន់ព្រៃទ្រនាប់ រវាងអភិរក្សដ្ឋានអង្គរ និង ប្រាសាទអង្គរវត្ត ។

• លើកស្ទួយតំលៃទេសភាព តាមរយៈការបង្កើនសកម្មភាពកសិកម្ម ហើយនិងការរៀបចំដែនដី ។

## មាត្រា ១៦ : ការចាត់ចែងគ្រប់គ្រងធនធានធម្មជាតិ

ក្នុងវិស័យការចាត់ចែងគ្រប់គ្រងធនធានធម្មជាតិ ត្រូវប្រកាន់យកទិសដៅដូចតទៅ :

ក _ ចំពោះរមណីយដ្ឋានវប្បធម៌ត្រូវការពារទាំងអស់ ( តំបន់ ១,២,៣,៤,៥ )

• គ្រប់គ្រងព្រៃឈើ និងតំបន់ព្រៃឈើ ដើម្បីបង្កើនជីវសាស្ត្រចំរុះ ។

• គ្រប់គ្រងរុក្ខជាតិ និង សត្វព្រៃ ដើម្បីថែរក្សា និង បង្កើនប្រភេទផ្សេង ៗ នៃសត្វព្រៃទាំងនោះ ។

• ការកាប់ឈើក្នុងរមណីយដ្ឋានត្រូវការពារ ត្រូវគោរពតាមបទបញ្ញត្តច្បាប់ ។

ខ _ ចំពោះតំបន់ ១

• បណ្តុះបណ្តាលឡើងវិញនូវព្រៃឈើធម្មជាតិ និងដីព្រៃឈើ ។

- ថែទាំដើមឈើនៅជុំវិញប្រាសាទ អោយបានគង់វង្ស ។
- បង្កើនសួនរុក្ខជាតិ និង ផ្លូវលំតាមជងព្រៃ ។
- រក្សាទុកការប្រើប្រាស់តាមប្រពៃណី នូវដីស្រែ និង វាលស្មៅសំរាប់សត្វ ។

គ - ចំពោះតំបន់ ២

- ចាប់ផ្តើមអនុវត្តកម្មវិធី ដាំដើមឈើ ដែលមានពូជនៅក្នុងតំបន់នេះ ។
- ជំរុញការដាំដុះពូជដំណាំណាដែលមានតំលៃខ្ពស់ (ស្វាយចន្ទី និង ឈើស៊ីផ្លែ ) ជុំវិញភូមិ ស្រុក ។

## មាត្រា ១៧ : អំពីអ្នករស់នៅតាមតំបន់

ចំពោះអ្នករស់នៅតាមតំបន់ ត្រូវប្រកាន់យកទិសដៅដូចតទៅ :

ក - ចំពោះរមណីយដ្ឋានវប្បធម៌ត្រូវការពារទាំងអស់ ( តំបន់ ១,២,៣,៤,៥ )

- ផ្តល់អាទិភាពការងារដល់អ្នករស់នៅក្នុងរមណីយដ្ឋានត្រូវការពារ ក្នុងវិស័យចាត់ចែងគ្រប់គ្រងថែទាំ រមណីយដ្ឋាន ។

ខ - ចំពោះតំបន់ ១

- ហាមឃាត់រាល់ការបង្កើតភូមិថ្មី ។
- ផ្តល់ជំនួយដល់អ្នករស់នៅក្នុងតំបន់ ដែលត្រូវទៅតាំងលំនៅឋានថ្មី ពិសេសផ្តល់ដី និង សំភារៈសំណង់ សំរាប់លំនៅឋាន និង សំណង់សហគមន៍ ។
- ផ្តល់អាទិភាព ដល់អ្នករស់នៅក្នុងរមណីយដ្ឋាន អោយច្បាប់អនុញ្ញាតធ្វើជំនួញតូចតាច ។

គ - ចំពោះតំបន់ ២

- រក្សាទុកភូមិបុរាណ ។
- ហាមឃាត់ការពង្រីកទីប្រជុំជនទាំងអស់ ។
- ធានាប្រាកដថា គ្រប់ការពង្រីកកម្មសិទ្ធិ ដែលមានស្រាប់ ត្រូវបានគោរពតាម លំនាំបុរាណ ។
- ផ្តល់ជំនួយក្នុងការរៀបចំសំណង់សហគមន៍ ដែលមានសារប្រយោជន៍ និង ជំរុញសំណង់ទេសចរណ៍តូច ៗ សំរាប់ជីវភាពក្នុងភូមិ ។

## មាត្រា ១៨ : អំពីវត្តអារាម

ចំពោះវត្តអារាម ត្រូវប្រកាន់យកទិសដៅដូចតទៅ :

ក - ចំពោះរមណីដ្ឋានវប្បធម៌ត្រូវការពារទាំងអស់ ( តំបន់ ១,២,៣,៤,៥ )

- រក្សាទុកសហគមន៍សាសនាដែលមាន ហើយថែទាំវត្តអារាមចាស់ ៗ ។
- ហាមឃាត់គ្រប់សកម្មភាពសាងសង់ ដែលធ្វើអោយខូចខាតផ្ទៃដី ។
- ជំរុញលើកទឹកចិត្ត គ្រប់សកម្មភាពបណ្តុះបណ្តាលបែបប្រពៃណី ។

ខ - ចំពោះតំបន់ ១

- មិនអនុញ្ញាតអោយមានវត្តថ្មី ឬ ទីតាំងសាសនា នៅក្នុងប្រាសាទនានា ។

• ហាមការស្នាក់អាស្រ័យពេលយប់ ក្រៅពីបរិវេណវត្តនៅក្នុងអង្គរ វត្តក្នុងប្រាសាទបាគង និង វត្តក្នុងប្រាសាទលលៃ ។

ឥ - ចំពោះតំបន់ ២

• ការបង្កើតវត្តថ្មី នៅតាមភូមិនានា ត្រូវគោរពតាម បទបញ្ញត្តច្បាប់ ។

មាត្រា ១៩ : អំពីឧស្សាហកម្ម និង ពាណិជ្ជកម្ម

ចំពោះសកម្មភាពឧស្សាហកម្ម និង ពាណិជ្ជកម្ម ត្រូវប្រកាន់យកទិសដៅដូចតទៅ :

ក - ចំពោះរមណីយដ្ឋានវប្បធម៌ត្រូវការពារទាំងអស់ ( តំបន់ ១,២,៣,៤,៥ )

• ហាមឃាត់ការអភិវឌ្ឍឧស្សាហកម្ម ឬ ពាណិជ្ជកម្មនៅក្នុងរមណីយដ្ឋានត្រូវការពារ លើក លែងតែ ឧស្សាហកម្ម ឬ ពាណិជ្ជកម្មតូច ៗ ចាំបាច់ ក្នុងការថែទាំ និងកិច្ចការពារទេសភាពវប្បធម៌ និង តំបន់បំរុងផ្នែកបុរាណវត្ថុវិទ្យា ។

ខ-ចំពោះតំបន់ ២

• បង្កើតរោងសិប្បកម្ម នៅក្នុងភូមិដែលមានស្រាប់ ឬ ក៏ក្នុងមជ្ឈមណ្ឌលទទួលទេសចរ ។

• ជំរុញសិប្បកម្មតូច ៗ និង ការផលិតវត្ថុអនុស្សាវរីយ៍ ។

មាត្រា ២០ : អំពីបណ្ដាញចរន្តអគ្គិសនី

ចំពោះបណ្ដាញចរន្តអគ្គិសនី ត្រូវប្រកាន់យកទិសដៅដូចតទៅ :

ចំពោះរមណីយដ្ឋានវប្បធម៌ត្រូវការពារទាំងអស់ ( តំបន់ ១,២,៣,៤,៥ )

• ហាមឃាត់ការរាយបណ្ដាញចរន្តអគ្គិសនី ដែលមានតង់ស្យុងខ្ពស់ នៅក្នុងរមណីយដ្ឋានត្រូវ ការពារ ។

• អនុញ្ញាតអោយដាក់បណ្ដាញចរន្តអគ្គិសនី មានតង់ស្យុងមធ្យម ដែលផ្ដល់អោយដោយ អគ្គិសនី នៅមូលដ្ឋានទោះ ដោយកុំអោយឃើញលេចធ្លោពេក ។

មាត្រា ២១ : ការទាក់ទាញអារម្មណ៍ចំពោះបរិដ្ឋាន

ចំពោះសកម្មភាពទាក់ទាញអារម្មណ៍ចំពោះបរិដ្ឋាន ត្រូវប្រកាន់យកទិសដៅដូចតទៅ :

ចំពោះរមណីយដ្ឋានវប្បធម៌ត្រូវការពារទាំងអស់ ( តំបន់ ១,២,៣,៤,៥ )

• ផ្ដើមអនុវត្តកម្មវិធី ដើម្បីអោយមានការទាក់ទាញអារម្មណ៍ ប្រជាជនមូលដ្ឋាន និង ទស្សនិកជនចំពោះសារៈសំខាន់ នៃ បេតិកភ័ណ្ឌវប្បធម៌ និង ចំពោះបញ្ហាបរិដ្ឋាន ។

មាត្រា ២២ : ការបណ្ដុះបណ្ដាលបុគ្គលិក

ចំពោះការបណ្ដុះបណ្ដាលបុគ្គលិក ត្រូវប្រកាន់យកទិសដៅដូចតទៅ :

ចំពោះរមណីយដ្ឋានវប្បធម៌ត្រូវការពារទាំងអស់ ( តំបន់ ១,២,៣,៤,៥ )

• បណ្ដុះបណ្ដាលកម្មករ សំរាប់ការដ្ឋានកំណាយ និង ការជួសជុល ។

• បណ្ដុះបណ្ដាលឆ្មាំឧទ្យាន និង បុគ្គលិកថែទាំ ។

• បណ្ណោះបណ្ដាលបុរាណវត្ថុវិទ្ធ ស្ថាបត្យករជួសជុល និងអ្នកប្រកបវិជ្ជាជីវៈផ្សេង ៗ ទៀត ក្នុងផ្នែកពាក់ព័ន្ធគ្រប់គ្រងបេតិកភ័ណ្ឌវប្បធម៌ ។

មាត្រា ២៣ : បញ្ញត្តិទាំងឡាយណា ដែលផ្ទុយ ទៅនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៤ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំដែនដី និង នគរោបនីយកម្ម រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ មានការពាក់ព័ន្ធ ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ២៥ : ព្រះរាជក្រឹត្យនេះ មានអានុភាពតតិយុត្តិ ចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ១៩៩៤

ន. សីហនុ

នរោត្តម សីហនុ






មាត្រដ្ឋាន ១ : ១៥០ ០០០

០ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ គម

# ផែនទីកំណត់តំបន់ និង ការចាត់ចែងគ្រប់គ្រង តំបន់សៀមរាប-អង្គរ

## រមណីយដ្ឋានវប្បធម៌ ដែលត្រូវការពារ ក្នុងតំបន់សៀមរាប-អង្គរ

### កំនត់សំគាល់

- រមណីយដ្ឋានមានប្រាសាទ
- ឧទ្យានបុរាណវត្ថុត្រូវការពារ
- ទេសភាពវប្បធម៌ត្រូវការពារ
- ចំណុចមានសារៈសំខាន់ផ្នែកបុរាណវត្ថុវិទ្យា នរវិទ្យា ឬ ប្រវត្តិវិទ្យា
- ស្ថានីយបុរាណវិទ្យា
- ខ្សែកោងបង្ហាញពីរយៈកំពស់ប្រែប្រួលក្នុងរង្វង់ ៥ម
- ផ្លូវទឹក, បារាយ, កសិណទឹក
- ផ្លូវជាតិ
- ផ្លូវក្នុងខេត្ត

ក្រសួងវប្បធម៌-យូណេស្កូ ០ អង្គរ ចារ. ១៩៩៤